# *ទីភ្នាក់ងារសុខភាពខោនធី LOS ANGELES*
# *សេចក្តីជូនដំណឹងពីការអនុវត្តឯកជនភាព*

**សេចក្តីជូនដំណឹងនេះពណ៌នាពីរបៀបដែលគេអាចប្រើនិងបង្ហាញព័ត៌មានវេជ្ជសាស្ត្ររបស់អ្នក និងរបៀបដែលអ្នកអាចចូលប្រើព័ត៌មាននេះ។ សូមអានវាឡើងវិញដោយប្រុងប្រយ័ត្ន។**

កាលបរិច្ឆេទចូលជាធរមានៈ ថ្ងៃសៅរ៍ ទី 30 ឧសភា 2017

---

## អ្នកដែលនឹងអនុវត្តតាមសេចក្តីជូនដំណឹងពីការអនុវត្តឯកជនភាពនេះ

សេចក្តីជូនដំណឹងនេះពណ៌នាពីការអនុវត្តឯកជនភាពដែលអនុវត្តដោយសមាជិកក្រុមការងាររបស់**នាយកដ្ឋានសេវាសុខភាព សុខភាពផ្លូវចិត្ត និងសុខភាពសាធារណៈ ខោនធី Los Angeles** ជារួមហៅថាទីភ្នាក់ងារសុខភាព(ទីភ្នាក់ងារ)។ សមាជិកក្រុមការងាររួមមានវេជ្ជបណ្ឌិត គ្រូពេទ្យប្រជាជន អ្នកជំនាញព្យាបាល អ្នកគ្រប់គ្រងករណី សិស្សនិស្សិត អ្នកស្ម័គ្រចិត្ត និងបុគ្គលិកថែទាំសុខភាពដទៃទៀតដែលជួយថែទាំអ្នកនៅក្នុងមន្ទីរពេទ្យរបស់ទីភ្នាក់ងារ។

## ការសន្យារបស់យើងស្តីពីព័ត៌មានសុខភាពរបស់អ្នក

ច្បាប់តម្រូវឲ្យទីភ្នាក់ងារៈ

- រក្សាទុកជាឯកជននិងសម្ងាត់នូវកំណត់ត្រាវេជ្ជសាស្ត្រនិងព័ត៌មានសុខភាពរបស់អ្នក ដែលហៅម្យ៉ាងទៀតថា"ព័ត៌មានសុខភាពមានការការពារ"។
- ជូនដំណឹងដល់អ្នកដោយពន្យល់ពីសិទ្ធិនិងកាតព្វកិច្ចផ្លូវច្បាប់ទាក់ទងនឹងព័ត៌មានសុខភាពរបស់អ្នក។
- ជម្រាបអ្នកពីការអនុវត្តឯកជនភាពនិងអនុវត្តតាមលក្ខខណ្ឌនៃសេចក្តីជូនដំណឹងនេះ។
- ជម្រាបអ្នកប្រសិនបើមានការរំលោភលើឯកជនភាពនៃព័ត៌មានសុខភាពរបស់អ្នក។
-

## ការប្រើប្រាស់និងបង្ហាញព័ត៌មានសុខភាពរបស់អ្នក

ប្រភេទខាងក្រោមនេះពណ៌នាពីវិធីផ្សេងៗដែលយើងអាចប្រើឬបង្ហាញព័ត៌មានសុខភាពរបស់អ្នកដោយមិនចាំបាច់ទទួលការអនុញ្ញាតពីអ្នកឡើយ។
ចំពោះការប្រើប្រាស់និងការបង្ហាញតាមប្រភេទនីមួយៗ យើងនឹងពន្យល់ពីអត្ថន័យរបស់វា និងផ្តល់ជូនឧទាហរណ៍មួយចំនួន។
មិនបានរៀបរាប់នូវរាល់ការប្រើប្រាស់និងការបង្ហាញនៅក្នុងប្រភេទមួយឡើយ។
ទោះជាយ៉ាងណាក្តី វិធីទាំងអស់ដែលយើងអាចប្រើនិងបង្ហាញនូវព័ត៌មានស្ថិតនៅក្នុងប្រភេទមួយក្នុងចំណោមប្រភេទទាំងឡាយ។

**ការព្យាបាល៖** យើងអាចប្រើនិងបង្ហាញព័ត៌មានសុខភាពរបស់អ្នកដើម្បីផ្តល់នូវការព្យាបាលវេជ្ជសាស្ត្រនិងសេវាកម្មពាក់ព័ន្ធជូនអ្នក។ យើងអាចចែករំលែកព័ត៌មានសុខភាពរបស់អ្នកជាមួយវេជ្ជបណ្ឌិត បុគ្គលិកវេជ្ជសាស្ត្រ អ្នកប្រឹក្សា បុគ្គលិកព្យាបាល ស្មៀន បុគ្គលិកគាំទ្រ និងបុគ្គលិកថែទាំសុខភាពដទៃទៀតដែលពាក់ព័ន្ធនឹងតំហែទាំសុខភាពរបស់អ្នក។ យើងក៏អាចចែករំលែកព័ត៌មានសុខភាព

ជាមួយអ្នកផ្តល់ការព្យាបាលសម្រាប់ការថែទាំសុខភាពរបស់អ្នកនៅពេលអនាគតសម្រាប់ហេតុផលព្យាបាលផ្សេងទៀត។ លើសពីនេះទៀត យើងអាចប្រើ ឬចែករំលែកព័ត៌មានសុខភាពរបស់អ្នកជាការឆ្លើយតបនឹងការសង្គ្រោះបន្ទាន់។

**ការចំណាយ៖** យើងអាចប្រើ និងបង្ហាញព័ត៌មានសុខភាពរបស់អ្នកដើម្បីរៀបចំវិក្កយបត្រ និងទទួលប្រាក់សម្រាប់ការព្យាបាលនិងសេវាកម្មនានាដែលអ្នកបានទទួល។ សម្រាប់គោលបំណងរៀបចំវិក្កយបត្រនិងបង់ប្រាក់ យើងអាចបង្ហាញព័ត៌មានសុខភាពរបស់អ្នកដល់ប្រភពចំណាយប្រាក់ ដូចជាក្រុមហ៊ុនធានារ៉ាប់រងក្រុមហ៊ុនថែទាំដែលបានចាត់ចែង, Medicare, Medicaid ឬអ្នកបង់ប្រាក់ភាគីទីបីផ្សេងទៀត។ ឧទាហរណ៍ យើងអាចផ្តល់ព័ត៌មានផែនការសុខភាពរបស់អ្នកអំពីការព្យាបាលដែលអ្នកបានទទួល ដើម្បីឲ្យផែនការសុខភាពរបស់អ្នកបង់ប្រាក់ឬសងប្រាក់ត្រលប់ដល់យើងវិញសម្រាប់ការព្យាបាល ឬយើងអាចទាក់ទងផែនការសុខភាពរបស់អ្នកដើម្បីបញ្ជាក់ពីការរ៉ាប់រងរបស់អ្នក ឬដើម្បីស្នើសុំការអនុញ្ញាតជាមុនសម្រាប់ការព្យាបាលដែលបានស្នើសុំ។

**ប្រតិបត្តិការថែទាំសុខភាព៖** យើងអាចប្រើនិងចែករំលែកព័ត៌មានសុខភាពរបស់អ្នកសម្រាប់គោលបំណងអាជីវកម្មរបស់ទីភ្នាក់ងារដូចជាការធានាគុណភាពនិងសកម្មភាពកែលម្អ ការពិនិត្យមើលសមត្ថភាពនិងលក្ខណៈសម្បត្តិរបស់អ្នកប្រកបវិជ្ជាជីវៈថែទាំសុខភាព ពិនិត្យមើលកំណត់ត្រាវេជ្ជសាស្ត្រ សេវាកម្មច្បាប់ តួនាទីសវនកម្ម និងគោលបំណងរដ្ឋបាលទូទៅ។ ឧទាហរណ៍ យើងអាចប្រើព័ត៌មានសុខភាពរបស់អ្នកដើម្បីពិនិត្យមើលឡើងវិញនូវការព្យាបាលនិងសេវាកម្មនានានិងវាយតម្លៃការអនុវត្តរបស់បុគ្គលិករបស់យើងក្នុងការថែទាំអ្នក។ យើងអាចរួមបញ្ចូលគ្នានូវព័ត៌មានសុខភាពអ្នកជំងឺរបស់យើង ដើម្បីសម្រេចថាតើ ទីភ្នាក់ងារគួរផ្តល់សេវាអ្វីបន្ថែមទៀត ឬថាតើការព្យាបាលថ្មីមានប្រសិទ្ធភាពដែរឬទេ។ ច្បាប់អាចតម្រូវឲ្យយើងចែករំលែកព័ត៌មានសុខភាពរបស់អ្នកជាមួយអ្នកតំណាងទីភ្នាក់ងារបទប្បញ្ញត្តិសហព័ន្ធនិងរដ្ឋដែលគ្រប់គ្រងអាជីវកម្មរបស់យើង។

**ដៃគូអាជីវកម្ម៖** ងអាចចែករំលែកព័ត៌មានសុខភាពរបស់អ្នកជាមួយដៃគូអាជីវកម្មរបស់យើង ដើម្បីឲ្យពួកគេអាចអនុវត្តការងារដែលយើងបានស្នើសុំឲ្យពួកគេបំពេញ។ អ្នកផ្តល់សេវាកម្មមួយចំនួនតាមរយៈដៃគូអាជីវកម្មរួមមានសេវាកម្មទារប្រាក់ ក្រុមហ៊ុនរក្សាទុកកំណត់ត្រា ឬទីប្រឹក្សាច្បាប់ឬគណនេយ្យ។ ដើម្បីការពារព័ត៌មានសុខភាពរបស់អ្នក យើងមានកិច្ចសន្យាជាលាយលក្ខណ៍អក្សរជាមួយដៃគូអាជីវកម្មរបស់យើងដែលទាមទារឲ្យពួកគេធានាសុវត្ថិភាពព័ត៌មានរបស់អ្នក។

**ការដោះដូរព័ត៌មានសុខភាព៖**
ពួកយើងរួមជាមួយនឹងអ្នកផ្តល់សេវាថែទាំសុខភាពដទៃទៀតនៅក្នុងតំបន់ Los Angeles អាចចូលរួមក្នុងការដោះដូរព័ត៌មានសុខភាព (HIE) មួយឬច្រើន។ HIE គឺជាប្រព័ន្ធព័ត៌មានទូទាំងសហគមន៍ដែលប្រើប្រាស់ដោយអ្នកផ្តល់សេវាថែទាំសុខភាព

ដែលបានចូលរួម ដើម្បីចែករំលែកព័ត៌មានសុខភាពរបស់អ្នកសម្រាប់គោលបំណងព្យាបាល។ ប្រសិនបើអ្នកត្រូវការការព្យាបាលពីអ្នកផ្តល់សេវាថែទាំសុខភាពមួយដែលបានចូលរួមក្នុងការដោះដូរមួយក្នុងចំណោមការដោះដូរទាំងនេះដែលមិនមានកំណត់ត្រាវេជ្ជសាស្ត្រឬព័ត៌មានសុខភាព ដែលអ្នកផ្តល់សេវាថែទាំសុខភាពអាចប្រើប្រព័ន្ធនេះដើម្បីប្រមូលព័ត៌មានសុខភាពរបស់អ្នកដើម្បីព្យាបាលអ្នក។ ឧទាហរណ៍ គាត់អាចទទួលលទ្ធផលតេស្តមន្ទីរពិសោធន៍ឬតេស្តដទៃទៀតដែលបានអនុវត្តរួចជាស្រេច ឬស្វែងរកការព្យាបាលមួយឬច្រើន ដែលអ្នកបានទទួលកន្លងមក។ យើងនឹងដាក់បញ្ចូលព័ត៌មានសុខភាពរបស់អ្នកនៅក្នុងប្រព័ន្ធនេះ។ ប្រសិនបើអ្នកមិនចង់ឲ្យគេចែករំលែកព័ត៌មានរបស់អ្នកជាមួយ HIE (ដកខ្លួនចេញ) ទេ ឬបានដកខ្លួនចេញពីការចូលរួមក្នុង HIE កន្លងមក និងចង់ចែករំលែកព័ត៌មានរបស់អ្នកជាមួយ HIE (ចូលរួម) សូមជូនដំណឹងដល់បុគ្គលិកចុះឈ្មោះ ឬការិយាល័យអាជីវកម្មនៅតាមកន្លែងដែលអ្នកទទួលការថែទាំសុខភាព។ បុគ្គលិកអាចជួយអ្នកផ្លាស់ប្តូរការសម្រេចចិត្តរបស់អ្នកដោយប្រើទម្រង់ *ផ្លាស់ប្តូរស្ថានភាពចែករំលែក HIE*។

**<u>បញ្ជីរាយឈ្មោះមន្ទីរពេទ្យ៖</u>**

មន្ទីរពេទ្យរបស់យើងរក្សាទុកបញ្ជីរាយឈ្មោះមួយដែលបង្ហាញពីអ្នកជំងឺដែលចូលសម្រាកពេទ្យ ដើម្បីឲ្យគ្រួសារនិងមិត្តភក្តិអាចទូរសព្ទឬមកសួរសុខទុក្ខ ឬដើម្បីឲ្យអ្នកអាចទទួលសំបុត្រ។ ប្រសិនបើអ្នកមិនជំទាស់ទេ យើងនឹងដាក់បញ្ចូលឈ្មោះ ទីកន្លែងរបស់អ្នកនៅក្នុងមន្ទីរពេទ្យនេះ ស្ថានភាពទូទៅ (ឧទា. ធម្មតា មិនប្រែប្រួល ធ្ងន់ធ្ងរ ។ល។) និងអង្គការសាសនានៅក្នុងបញ្ជីរាយឈ្មោះរបស់មន្ទីរពេទ្យ។ ព័ត៌មានបញ្ជីរាយឈ្មោះ

លើកលែងតែអង្គការសាសនាចេញ ព័ត៌មាននឹងត្រូវបង្ហាញដល់មនុស្សដែលសួររកឈ្មោះអ្នក លុះណាតែអ្នកស្នើសុំមិនឲ្យយើងដាក់បញ្ចូល ឬកំណត់ព័ត៌មាននេះ។ ការផ្តល់នូវអង្គការសាសនារបស់អ្នកគឺធ្វើតាមជម្រើសរបស់អ្នក។ ប្រសិនបើអ្នកសម្រេចចិត្តផ្តល់ព័ត៌មាននេះដល់យើង ព័ត៌មាននេះអាចផ្តល់ជូនដល់សមាជិកបព្វជិតសាសនាដូចជាបព្វជិត ឬអ្នកប្រដៅសាសនា ទោះបីជាពួកគេមិនសួររកឈ្មោះអ្នកក៏ដោយ។

**<u>ការរំលឹកពីការណាត់ជួប៖</u>**

យើងអាចប្រើនិងបង្ហាញព័ត៌មានសុខភាពរបស់អ្នកដើម្បីទាក់ទងអ្នកជាការក្រើនរំលឹកថាអ្នកមានការណាត់ជួបនៅមន្ទីរពេទ្យមួយក្នុងចំណោមមន្ទីរពេទ្យទាំងឡាយតាមរយៈសំបុត្រស្តង់ដារ(បណ្តប្រៃសនីយ៍) ទូរសព្ទ អ៊ីម៉ែល ឬសារអត្ថបទ។

**ពិភាក្សាពីការព្យាបាល ជម្រើសនានា និងអត្ថប្រយោជន៍និងសេវាកម្មពាក់ព័ន្ធនឹងសុខភាពដទៃទៀតជាមួយអ្នក៖**

យើងអាចប្រើនិងបង្ហាញព័ត៌មានសុខភាពរបស់អ្នកដើម្បីប្រាប់អ្នកអំពីស្ថានភាពសុខភាពរបស់អ្នកឬដើម្បីណែនាំពីជម្រើសព្យាបាលដែលអាចមាន។ យើងអាចជម្រាបអ្នកអំពីអត្ថប្រយោជន៍ទាក់ទងនឹងសុខភាព ថ្នាក់អប់រំសុខភាពឬសេវាកម្មនានា(ដូចជាលក្ខណៈសម្បត្តិសមស្របក្នុងការទទួលបានអត្ថប្រយោជន៍ Medicaid ឬសន្តិសុខសង្គម) ដែលអ្នកអាចមានចំណាប់អារម្មណ៍។

**<u>ចំពោះបុគ្គលដែលពាក់ព័ន្ធនឹងការថែទាំសុខភាពឬការចំណាយលើការថែទាំសុខភាពរបស់អ្នក៖</u>**

យើងអាចប្រើនិងបង្ហាញព័ត៌មានសុខភាពរបស់អ្នកដល់សមាជិកគ្រួសារ សាច់ញ្ញាត្តិ មិត្តភក្តិជិតស្និទ្ធ ឬបុគ្គលដទៃទៀតដែលពាក់ព័ន្ធនឹងការថែទាំសុខភាពឬការចំណាយលើការថែទាំសុខភាពរបស់អ្នក ប្រសិនបើយើងទទួលបានការព្រមព្រៀងផ្ទាល់មាត់ពីអ្នក ឬប្រសិនបើយើងផ្តល់ឱកាសដល់អ្នកធ្វើការជំទាស់ចំពោះការបង្ហាញបែបនេះ
និងមិនអ្នកមិនលើកការជំទាស់ទេនោះ។
ប្រសិនបើអ្នកមិនអាចយល់ព្រមឬជំទាស់នៅពេលដែលយើងផ្តល់ឱកាសដល់អ្នកក្នុងការធ្វើដូច្នេះទេ យើងអាចសម្រេចថាវាផ្តល់អត្ថប្រយោជន៍ដល់អ្នក ដោយផ្អែកលើការវិនិច្ឆ័យតាមវិជ្ជាជីវៈរបស់យើង ដើម្បីចែករំលែក ព័ត៌មានសុខភាពរបស់អ្នក ដូចជាប្រសិនបើអ្នកលែងធ្វើអ្វីកើតឬនៅអំឡុងពេលសង្គ្រោះបន្ទាន់។

**<u>គោលបំណងសម្រាលទុក្ខលំបាក៖</u>**
យើងអាចបង្ហាញព័ត៌មានសុខភាពរបស់អ្នកដល់អង្គភាពដែលជួយសម្រាលទុក្ខលំបាក ដើម្បីឲ្យគេអាចជូនដំណឹងដល់គ្រួសារអ្នកអំពីលក្ខខណ្ឌ ស្ថានភាពនិងទីតាំងរបស់អ្នក។ យើងនឹងផ្តល់ឱកាសដល់អ្នកព្រមព្រៀងឬជំទាស់ចំពោះការបង្ហាញព័ត៌មាននេះ លុះណាតែយើងសម្រេចថាយើងចាំបាច់ត្រូវបង្ហាញ ព័ត៌មានសុខភាពរបស់អ្នកដើម្បីឆ្លើយតបទៅនឹងកាលៈទេសៈបន្ទាន់។

**<u>គោលបំណងបំណងសុខភាពសាធារណៈ៖</u>**
យើងអាចបង្ហាញព័ត៌មានសុខភាពរបស់អ្នកសម្រាប់សកម្មភាពសុខភាពសាធារណៈ។ ជាទូទៅសកម្មភាពទាំងនេះរួមមាន៖

- ទប់ស្កាត់និងគ្រប់គ្រងជំងឺ ការរងរបួស ឬពិការភាព
- រាយការណ៍ពីកំណើតនិងមរណភាព
- រាយការណ៍ពីការរំលោភនិងមិនយកចិត្តទុកដាក់លើកុមារ
- រាយការណ៍ពីប្រតិកម្មចំពោះការប្រើប្រាស់ឱសថឬបញ្ហាជាមួយផលិតផល
- ជូនដំណឹងដល់ប្រជាជនពីការកោះប្រមូលផលិតផលដែលកំពុងប្រើប្រាស់ទៅវិញ
- ជូនដំណឹងដល់អ្នកដែលអាចទទួលរងជំងឺ ឬអាចស្ថិតនៅក្នុងហានិភ័យចំពោះការប៉ះពាល់ ឬការរាលដាលជំងឺ ឬលក្ខខណ្ឌមួយ
- ជូនដំណឹងដល់អាជ្ញាធររដ្ឋាភិបាលពាក់ព័ន្ធ ប្រសិនបើយើងជឿជាក់ថាអ្នកជាជនរងគ្រោះនៃការរំលោភបំពាន ការមិនយកចិត្តទុកដាក់ ឬអំពើហិង្សាក្នុងគ្រួសារ។

**<u>សម្រាប់គោលបំណងគ្រប់គ្រងសុខភាព៖</u>**
យើងអាចបង្ហាញព័ត៌មានសុខភាពរបស់អ្នកដល់ទីភ្នាក់ងារគ្រប់គ្រងសុខភាពសម្រាប់គោលបំណងបំណងដែលច្បាប់អនុញ្ញាត។ ឧទាហរណ៍ យើងអាចបង្ហាញព័ត៌មានសុខភាពរបស់អ្នកសម្រាប់សកម្មភាពសវនកម្ម ស៊ើបអង្កេត ត្រួតពិនិត្យ ការផ្តល់អំណាច ការផ្តល់អាជ្ញាបណ្ណ និងសកម្មភាពខាងវិន័យ។

**<u>ការស្រាវជ្រាវ៖</u>**
ព័ត៌មានសុខភាពរបស់អ្នកអាចត្រូវផ្តល់ទៅឲ្យអ្នកស្រាវជ្រាវប្រសិនបើអ្នកអនុញ្ញាតឲ្យប្រើប្រាស់វាសម្រាប់គោលបំណងស្រាវជ្រាវ។ នៅក្នុងស្ថានភាពខ្លះ
យើងអាចបង្ហាញព័ត៌មានសុខភាពរបស់អ្នកដល់អ្នកស្រាវជ្រាវដែលរៀបចំពិធីសារស្រាវជ្រាវ ឬប្រសិនបើស្ថាប័នគណៈកម្មការក្រុមប្រឹក្សាត្រួតពិនិត្យ (IRB) របស់យើងកំណត់ថាមិនចាំបាច់ទទួលការអនុញ្ញាតឡើយ។ គណៈកម្មការ IRB ទទួលខុសត្រូវដោយធានានូវការការពារប្រធានបទនៅក្នុងការស្រាវជ្រាវ។

យើងក៏អាចផ្តល់ព័ត៌មានសុខភាពមានកំណត់របស់អ្នក(ដោយមិនបង្ហាញឈ្មោះ អាសយដ្ឋាន ឬគ្រឿងកំណត់អត្តសញ្ញាណផ្ទាល់ដទៃទៀត) សម្រាប់ការស្រាវជ្រាវ ប្រតិបត្តិការសុខភាពសាធារណៈ ប្រតិបត្តិការថែទាំសុខភាព ប៉ុន្តែប្រសិនបើបុគ្គលឬអង្គភាពដែលទទួលបានព័ត៌មាននោះចុះហត្ថលេខាលើកិច្ចព្រមព្រៀងការពារ ព័ត៌មាននេះ និងមិនប្រើវាដើម្បីកំណត់អត្តសញ្ញារបស់អ្នក។

**<u>ចំណាត់ការផ្លូវច្បាប់និងរដ្ឋបាល៖</u>** ប្រសិនបើអ្នកជាប់ពាក់ព័ន្ធនឹងបណ្តឹងផ្លូវច្បាប់ឬជម្លោះ យើងអាចបង្ហាញព័ត៌មានសុខភាពរបស់អ្នក ដើម្បីឆ្លើយតបនឹងដីកាតុលាការនិងរដ្ឋបាល។ យើងក៏អាចបង្ហាញព័ត៌មានសុខភាពរបស់អ្នកដើម្បីឆ្លើយតបនឹងដីកាកោះ សំណើស្រាវជ្រាវ ឬនីតិវិធីច្បាប់ដទៃទៀត ដោយនរណាម្នាក់ផ្សេងទៀតដែលពាក់ព័ន្ធនឹងជម្លោះនេះ តែប្រសិនបើការខិតខំប្រឹងប្រែងនេះធ្វើឡើងដើម្បីប្រាប់អ្នកអំពីសំណើនេះ (ដែលអាចរាប់បញ្ចូលនូវសេចក្តីជូនដំណឹងជាលាយលក្ខណ៍អក្សរដល់អ្នក) ឬដើម្បីទទួលបានបទបញ្ជាការពារ ព័ត៌មានសុខភាពដែលបានស្នើសុំ។

**<u>ការអនុវត្តច្បាប់៖</u>** យើងអាចបង្ហាញព័ត៌មានសុខភាពរបស់អ្នកដល់ទីភ្នាក់ងារអនុវត្តច្បាប់៖

- ប្រសិនបើប៉ូលិសនាំអ្នកទៅកាន់មន្ទីរពេទ្យ ឬសរសេរជាឯកសារថាកាលៈទេសៈតឹងរឹងកើតឡើង ដើម្បីធ្វើតេស្តឈាមរបស់អ្នករកមើលជាតិអាល់កុលឬគ្រឿងញៀន ឬ
- ប្រសិនបើប៉ូលិសបង្ហាញដីកាឆែកឆេរមានសុពលភាព ឬ
- ប្រសិនបើប៉ូលិសបង្ហាញដីកាតុលាការមានសុពលភាព ឬ
- ដើម្បីរាយការណ៍ពីការរំលោភ ការមិនយកចិត្តទុកដាក់ ឬការវាយប្រហារដែលតម្រូវឬអនុញ្ញាតដោយច្បាប់ ឬ
- ដើម្បីរាយការណ៍ពីការគំរាមកំហែងមួយចំនួនដល់ភាគទីបីឬឧក្រិដ្ឋកម្មដែលប្រព្រឹត្តិនៅក្នុងបរិវេណ ឬ
- ដើម្បីកំណត់អត្តសញ្ញាណ ឬរកជនសង្ស័យ អ្នករត់គេចខ្លួន សាក្សីជាសម្ភារៈ ឬមនុស្សដែលបាត់ខ្លួន ប្រសិនបើច្បាប់តម្រូវឬអនុញ្ញាត ឬ
- ដើម្បីរាយការណ៍ពីការចេញពីមន្ទីរពេទ្យរបស់អ្នក ប្រសិនបើអ្នកត្រូវបានឃុំខ្លួនដោយមិនស្ម័គ្រចិត្ត បន្ទាប់ពីមន្ត្រីអនុវត្តច្បាប់បានផ្តួចផ្តើមការឃុំខ្លួនរយៈពេល 72 ម៉ោងសម្រាប់វាយតម្លៃជំងឺផ្លូវចិត្តនិងជូនដំណឹងតាមការស្នើសុំ។

**<u>អំណោយសរីរាង្គនិងជាលិកា៖</u>** ប្រសិនបើអ្នកជាអ្នកផ្តល់អំណោយសរីរាង្គ យើងអាចបង្ហាញព័ត៌មានសុខភាពរបស់អ្នក ដល់អង្គភាពពាក់ព័ន្ធនឹងការធ្វើអំណោយសរីរាង្គនិងជាលិកា។

**<u>អ្នកធ្វើសពវិភាគ អ្នកត្រួតពិនិត្យវេជ្ជសាស្ត្រ នាយកបុណ្យសព្វ និងព័ត៌មានអំពីមរណជន៖</u>**
នៅពេលច្បាប់តម្រូវ គេអាចបង្ហាញព័ត៌មានសុខភាពរបស់អ្នកដល់អ្នកធ្វើសព្វវិភាគ ឬអ្នកត្រួតពិនិត្យវេជ្ជសាស្ត្រ។ ឧទាហរណ៍ ប្រការនេះអាចចាំបាច់ដើម្បីកំណត់អត្តសញ្ញាណអ្នកស្លាប់ឬកំណត់មូលហេតុនៃការស្លាប់។ យើងក៏អាចបង្ហាញព័ត៌មានសុខភាពមានកំណត់ទៅដល់ផ្នែកធ្វើបុណ្យសព្វផងដែរ។ យើងក៏អាចផ្តល់ព័ត៌មានសុខភាពដល់សមាជិកក្រុមគ្រួសារឬមិត្តភក្តិអ្នកស្លាប់ផងដែរប្រសិនបើពួកគេពាក់ព័ន្ធនឹងការថែទាំបុគ្គលដែលស្លាប់នោះឬ ចេញថ្លៃចំណាយសម្រាប់

ការថែទាំសុខភាពនោះមុននឹងស្លាប់ ហើយប្រសិនបើព័ត៌មានសុភាពនោះមានការពាក់ព័ន្ធ។ ទោះជាយ៉ាងណាក្តី យើងនឹងមិនធ្វើដូច្នេះឡើយ ប្រសិនបើព័ត៌មានសុខភាពនេះមិនពាក់ព័ន្ធនឹងការពាក់ព័ន្ធរបស់ពួកគេ ឬប្រសិនបើយើងដឹងថាបុគ្គលដែលស្លាប់មិនចង់ឲ្យយើងចែករំលែកព័ត៌មាននេះ។

**ដើម្បីបង្ការការគំរាមកំហែងធ្ងន់ធ្ងរចំពោះសុខភាពឬសុវត្ថិភាព៖**
យើងអាចប្រើប្រាស់ឬបង្ហាញព័ត៌មានមួយចំនួនអំពីអ្នកនៅពេលចាំបាច់ដើម្បីការពារការគំរាមកំហែងធ្ងន់ធ្ងរចំពោះសុខភាពនិងសុវត្ថិភាពរបស់អ្នក ឬ អ្នកដទៃ។ ប៉ុន្តែការបង្ហាញបែបនេះណាមួយ គឺធ្វើឡើងតែតាមកម្រិតដែលច្បាប់និងបទប្បញ្ញត្តិសហព័ន្ធរដ្ឋ និងមូលដ្ឋានតម្រូវនិងអនុញ្ញាតប៉ុណ្ណោះ។

**បុគ្គលិកយោធា៖** ប្រសិនបើអ្នកជាសមាជិកកងកម្លាំងប្រដាប់អាវុធ យើងអាចបង្ហាញព័ត៌មានសុខភាពរបស់អ្នកដូចដែលកំណត់ដោយអាជ្ញាធរយោធា ឬក្រសួងកិច្ចការអតីតយុទ្ធជន។

**មុខងាររដ្ឋាភិបាលជំនាញ និងសន្តិសុខជាតិ៖**
យើងអាចបង្ហាញព័ត៌មានសុខភាពរបស់អ្នកដល់មន្ត្រីសហព័ន្ធដើម្បីអង្កេតបណ្តឹងផ្លូវច្បាប់ ការស៊ើបការណ៍ប្រឆាំង និងសកម្មភាពសន្តិសុខជាតិដទៃទៀតដែលច្បាប់អនុញ្ញាត។ យើងអាចបង្ហាញព័ត៌មានសុខភាពរបស់អ្នកដល់មន្ត្រីសហព័ន្ធដែលផ្តល់ការការពារដល់ប្រធានាធិបតី មនុស្សដទៃ ប្រមុខរដ្ឋបរទេស ឬធ្វើការស៊ើបអង្កេត។

**សំណងបុគ្គលិក៖**
យើងអាចបង្ហាញព័ត៌មានសុខភាពរបស់អ្នកតាមការអនុញ្ញាតដោយច្បាប់សំណងបុគ្គលិក ឬកម្មវិធីពាក់ព័ន្ធ។ ឧទាហរណ៍ យើងអាចបង្ហាញព័ត៌មានសុខភាពរបស់អ្នកដែលទាក់ទងនឹងរបួសនិងជំងឺទាក់ទងនឹងការងារ ដើម្បីទាមទារឲ្យអ្នកគ្រប់គ្រង ក្រុមហ៊ុនធានារ៉ាប់រង និងអ្នកផ្សេងទៀតទទួលខុសត្រូវចំពោះការវាយតម្លៃលើការទាមទារអត្ថប្រយោជន៍សំណងបុគ្គលិករបស់អ្នក។

**តាមច្បាប់តម្រូវ៖** យើងនឹងបង្ហាញព័ត៌មានសុខភាពរបស់អ្នកនៅពេលច្បាប់សហព័ន្ធ រដ្ឋ និងមូលដ្ឋានតម្រូវឲ្យធ្វើដូច្នេះ។ ឧទាហរណ៍ ច្បាប់តម្រូវឲ្យយើងរាយការណ៍ពីប្រភេទរបួសមួយចំនួន។

**ការជូនដំណឹងពីការរំលោភ៖**
យើងអាចប្រើប្រាស់និងបង្ហាញព័ត៌មានសុខភាពរបស់អ្នកដើម្បីប្រាប់អ្នកប្រសិនបើមានការចូលទៅប្រើប្រាស់ព័ត៌មានរបស់អ្នកដោយមិនមានការអនុញ្ញាតឬខុសច្បាប់ ដូចជានៅពេលនរណាម្នាក់ដែលមិនមានការអនុញ្ញាតឲ្យមើលព័ត៌មានសុខភាពរបស់អ្នក មើលព័ត៌មានរបស់អ្នក ឬព័ត៌មានសុខភាពរបស់អ្នកត្រូវបានបាត់បង់ដោយចៃដន្យឬត្រូវគេលួច។ យើងនឹងរាយការណ៍នូវឧប្បទ្ទវហេតុទាំងនេះ ដល់អាជ្ញាធររដ្ឋនិងសហព័ន្ធ និងអាចត្រូវការប្រើព័ត៌មានសុខភាពរបស់អ្នកដើម្បីធ្វើដូច្នេះ។ ប្រសិនបើបញ្ហានេះកើតឡើង យើងនឹងផ្តល់ការជូនដំណឹងជាលាយលក្ខណ៍អក្សរដល់អ្នកតាមរយៈសំបុត្រថ្នាក់ទី១ដល់អាសយដ្ឋានចុងក្រោយដែលគេស្គាល់។

**ច្បាប់ពិសេសសម្រាប់ការបង្ហាញព័ត៌មានផ្លូវចិត្ត ការប្រើគ្រឿងញៀន និងព័ត៌មានទាក់ទងនឹង HIV៖** ដើម្បីបង្ហាញនូវព័ត៌មានសុភាពអំពីលក្ខខណ្ឌផ្លូវចិត្ត ការប្រើប្រាស់គ្រឿងញៀន ឬការធ្វើតេស្តនិងព្យាបាលដែលទាក់ទងនឹង HIV ច្បាប់ពិសេសអាចយកមកអនុវត្ត។ ជាទូទៅ ព័ត៌មានសុខភាពដែលទាក់ទងនឹងការថែទាំលក្ខខណ្ឌផ្លូវចិត្ត ការប្រើប្រាស់គ្រឿងញៀន ឬការធ្វើតេស្តនិងព្យាបាលដែលទាក់ទងនឹង HIV មិនអាចបង្ហាញដោយមិនមានការអនុញ្ញាត ពីអ្នកឬដីកាតុលាការឡើយ។ មានការលើកលែងចំពោះច្បាប់ទូទៅទាំងនេះ។ ឧទាហរណ៍ លទ្ធផលតេស្ត HIV អាចបង្ហាញដល់អ្នកផ្តល់ការថែទាំសុខភាពដោយមិនមានការអនុញ្ញាត ជាលាយលក្ខណ៍អក្សរ។

**អ្នកទោស៖** បើអ្នកជាអ្នកទោសឬស្ថិតនៅក្រោមការឃ្លាំមើលរបស់មន្ត្រីអនុវត្តច្បាប់ យើងអាចបញ្ចេញព័ត៌មានសុខភាពរបស់អ្នកដល់ស្ថាប័នកែប្រែឬមន្ត្រីអនុវត្តច្បាប់។ ការបញ្ចេញនេះមានការចាំបាច់ សម្រាប់ស្ថាប័នផ្តល់ការថែទាំសុខភាពដល់អ្នកនិងដើម្បីសុវត្ថិភាពនិងសន្តិសុខរបស់ស្ថានប័នកែប្រែ។

**ការរៃអង្គាសប្រាក់៖**
យើងអាចប្រើព័ត៌មានអំពីអ្នកដើម្បីទាក់ទងលោកអ្នករៃអង្គាសប្រាក់សម្រាប់មន្ទីរពេទ្យឬគ្លីនិករបស់យើង។ យើងនឹងកំណត់ព័ត៌មានអំពីអ្នកមួយចំនួនដែលយើងបង្ហាញដូចជាឈ្មោះ អាសយដ្ឋាន និងលេខទូរសព្ទរបស់អ្នកនិងកាលបរិច្ឆេទដែលអ្នកបានទទួលការព្យាបាលឬសេវាកម្មនានានៅតាមមន្ទីរពេទ្យរបស់យើង។ ឧទាហរណ៍ យើងអាចផ្ញើលិខិតជូនអ្នកដោយសួរថាតើអ្នកចង់ធ្វើអំណោយដែរឬទេ។ អ្នកអាចជ្រើសរើសមិនឲ្យគេទាក់ទងសម្រាប់ការងាររៃអង្គាសប្រាក់។ ប្រសិនបើយើងផ្ញើជូនអ្នកនូវព័ត៌មានអំពីការងាររៃអង្គាសប្រាក់របស់យើង យើងនឹងដាក់បញ្ចូល នូវវិធីសាមញ្ញមួយដើម្បីឲ្យអ្នកស្នើសុំឲ្យយើងកុំទាក់ទងអ្នកនៅពេលអនាគតសម្រាប់ការងាររៃអង្គាសប្រាក់របស់យើង។

## ការប្រើប្រាស់និងការបង្ហាញដទៃទៀត

លើកលែងដូចបានពណ៌នានៅក្នុងសេចក្តីជូនដំណឹងនេះ ឬដូចដែលច្បាប់រដ្ឋឬសហព័ន្ធអនុញ្ញាត យើងនឹងមិនប្រើប្រាស់ឬចែករំលែកព័ត៌មានសុខភាពរបស់អ្នកដោយមិនមានការអនុញ្ញាត ជាលាយលក្ខណ៍អក្សរឡើយ។ ឧទាហរណ៍ យើងមិនអាចប្រើឬបង្ហាញ ព័ត៌មានសុខភាពរបស់អ្នកសម្រាប់គោលបំណងធ្វើទីផ្សារ ឬលក់ដូរវាដោយមិនមាន ការអនុញ្ញាតជាលាយលក្ខណ៍អក្សរពីអ្នកឡើយ។ ប្រសិនបើអ្នកចុះហត្ថលេខាលើការអនុញ្ញាត ហើយក្រោយមកប្តូរចិត្តវិញ អ្នកអាចជូនដំណឹងដល់យើងជាលាយលក្ខណ៍អក្សរ។ ការធ្វើដូច្នេះនឹងបញ្ឈប់ការប្រើប្រាស់និងការបង្ហាញព័ត៌មានរបស់អ្នកក្នុងពេលអនាគត ប៉ុន្តែនឹងមិនតម្រូវឲ្យយើងទាមទារយកមកវិញនូវព័ត៌មានដែលយើងបានផ្តល់ឲ្យគេរួចហើយឡើយ។

## សិទ្ធិរបស់អ្នកអំពីព័ត៌មានសុខភាពរបស់អ្នក

អ្នកមានសិទ្ធិលើព័ត៌មានសុខភាពរបស់អ្នកដូចតទៅ ដែលអ្នកអាចអនុវត្តដោយដាក់សំណើនៅ

មន្ទីរពេទ្យដែលអ្នកទទួលការថែទាំសុខភាព។ ដើម្បីឲ្យអ្នកមានភាពងាយស្រួល, ទម្រង់ដែលអាចអនុវត្តបានអាចមាននៅលើវិបសៃថ៍របស់យើងតាម dhs.lacounty.gov,dmh.lacounty.gov ឬ publichealth.lacounty.gov។

**សិទ្ធិស្នើសុំដាក់កំហិតចំពោះព័ត៌មានសុខភាពរបស់អ្នក៖**

អ្នកមានសិទ្ធិស្នើសុំឲ្យយើងអនុវត្តតាមការដាក់កំហិតពិសេសនៅពេលប្រើឬផ្តល់ព័ត៌មានសុខភាពរបស់អ្នកសម្រាប់ការព្យាបាល ការចំណាយ ឬប្រតិបត្តិការថែទាំសុខភាព។ អ្នកអាចស្នើសុំការដាក់កំហិតលើកំណត់ត្រាសុខភាពដែលយើងផ្តល់ឲ្យនរណាម្នាក់ដែលពាក់ព័ន្ធនឹងការថែទាំសុខភាពរបស់អ្នក ឬការចំណាយចំពោះការថែទាំសុខភាពរបស់អ្នក។ ឧទាហរណ៍ អ្នកអាចស្នើសុំមិនឲ្យយើងចែករំលែកព័ត៌មានមួយចំនួនជាមួយសហព័ទ្ធរបស់អ្នក។

យើងមិនចាំបាច់ព្រមព្រៀងចំពោះសំណើរបស់អ្នកឡើយ ហើយនឹងជម្រាបអ្នកប្រសិនបើយើងមិនគោរពតាមសំណើរបស់អ្នក។ ទោះជាយ៉ាងនេះក៏ដោយ ប្រសិនបើយើងពិតជាព្រមព្រៀង យើងនឹងគោរពតាម លុះណាតែត្រូវការចាំបាច់នូវព័ត៌មានសុខភាពដើម្បីធ្វើការព្យាបាលអ្នកក្នុងគ្រាអាសន្ន។ ប្រសិនបើយើងចែករំលែក ព័ត៌មានសុខភាពរបស់អ្នកដែលមានការដាក់កំហិតជាមួយអ្នកផ្តល់សេវាថែទាំសុខភាពសម្រាប់ការព្យាបាលបន្ទាន់ យើងនឹងស្នើសុំឲ្យអ្នកផ្តល់ការថែទាំសុខភាពកុំប្រើប្រាស់ឬបង្ហាញព័ត៌មាននេះបន្តទៀត។

**សិទ្ធិស្នើសុំការដាក់កំហិតនៅពេលអ្នកចេញលុយពីហោប៉ៅរបស់ខ្លួន៖**

អ្នកមានសិទ្ធិស្នើសុំការដាក់កំហិតចំពោះការបង្ហាញនូវ ព័ត៌មានសុខភាពរបស់អ្នកដល់ផែនការសុខភាពសម្រាប់គោលបំណងចំណាយប្រាក់ឬប្រតិបត្តិការថែទាំសុខភាព ប្រសិនបើអ្នកឬនរណាម្នាក់ផ្សេងជាអ្នកចេញប្រាក់ពេញពី

ហោប៉ៅសម្រាប់មុខចំណាយឬសេវាថែទាំសុខភាព។ អ្នកត្រូវតែយល់ព្រមចំពោះសំណើរបស់អ្នក លុះណាតែច្បាប់តម្រូវឲ្យយើងចែករំលែកព័ត៌មានរបស់អ្នក។ ប្រសិនបើអ្នកចេញប្រាក់ពេញពីហោប៉ៅសម្រាប់មុខចំណាយថែទាំសុខភាព ហើយអ្នកចង់ស្នើសុំការដាក់កំហិតពិសេសនេះ អ្នកត្រូវតែដាក់សំណើជាលាយលក្ខណ៍អក្សរទៅមន្ទីរពេទ្យដែលអ្នកទទួលបានការថែទាំសុខភាព។

**សិទ្ធិជ្រើសរើសនរណាម្នាក់តំណាងឲ្យអ្នក៖**

ប្រសិនបើអ្នកបានផ្តល់លិខិតប្រគល់សិទ្ធិអំណាចវេជ្ជសាស្ត្រដល់នរណាម្នាក់ ឬប្រសិនបើនរណាម្នាក់ជាអាណាព្យាបាលស្របច្បាប់របស់អ្នក ជននោះអាចប្រើសិទ្ធិរបស់អ្នកនិងសម្រេចអំពីព័ត៌មានសុខភាពរបស់អ្នក។ យើងនឹងធ្វើឲ្យប្រាកដថាជននេះមានសិទ្ធអំណាចសមស្រប មុននឹងយើងចាត់វិធានការណាមួយ។

**សិទ្ធិទទួលទំនាក់ទំនងសម្ងាត់៖**

អ្នកមានសិទ្ធិស្នើឡើងថាយើងគួរតែទាក់ទងជាមួយអ្នកអំពីការណាត់ជួប ឬបញ្ហាដទៃទៀតដែលទាក់ទងនឹងការព្យាបាលអ្នកតាមវិធីជាក់លាក់មួយ (ឧទា. គ្រាន់តែទូរសព្ទហៅអ្នកពេលធ្វើការ)។ អ្នកត្រូវតែបញ្ជាក់ច្បាស់ពីមធ្យោបាយឬទីកន្លែងដែលយើងអាចទាក់ទងអ្នក។ យើងនឹងផ្តល់ជូននូវសំណើសមហេតុផលទាំងអស់។

**សិទ្ធិចូលប្រើ ត្រួតពិនិត្យ និងថតចម្លងព័ត៌មានសុខភាពរបស់អ្នក៖**

ដោយមានការលើកលែងមួយចំនួន ដូចជាកំណត់ត្រា កំណត់សម្គាល់ការព្យាបាលចិត្តសាស្ត្រ ដែលបានពិចារណា អ្នកមានសិទ្ធិមើលនិងទទួលកំណត់ត្រាវេជ្ជសាស្ត្រថែទាំសុខភាពអ្នកដែលយើងមានមួយច្បាប់។ ដើម្បីពិនិត្យនិងថតចម្លងកំណត់ត្រាវេជ្ជសាស្ត្រ អ្នកត្រូវតែដាក់សំណើជាលាយលក្ខណ៍អក្សរទៅកាន់មន្ទីរពេទ្យដែលអ្នកទទួលការថែទាំសុខភាព។ ប្រសិនបើអ្នកស្នើសុំច្បាប់ចម្លងកំណត់ត្រាវេជ្ជសាស្ត្ររបស់អ្នក យើងអាចគិតថ្លៃសម្រាប់ការថតចម្លង ការផ្ញើតាមប្រៃសនីយ៍ ឬការផ្គត់ផ្គង់ដែលទាក់ទងនឹងសំណើរបស់អ្នក។ ប្រសិនបើយើងបដិសេធសំណើរបស់អ្នក យើងនឹងផ្តល់ជូនអ្នកនូវការសម្រេចជាលាយលក្ខណ៍អក្សរ។

**<u>សិទ្ធិកែប្រែព័ត៌មានសុខភាពរបស់អ្នក៖</u>** ប្រសិនបើអ្នកគិតថា ព័ត៌មានសុខភាពដែលមាននៅក្នុងកំណត់ត្រាវេជ្ជសាស្ត្ររបស់អ្នកមិនត្រឹមត្រូវ ឬមិនពេញលេញ អ្នកអាចស្នើសុំឲ្យយើងកែតម្រូវឬធ្វើបច្ចុប្បន្នភាពព័ត៌មាននេះ។ អ្នកមានសិទ្ធិស្នើសុំធ្វើការកែប្រែវាដរាបណាយើងរក្សាទុកព័ត៌មានសុខភាពនេះ។ ដើម្បីស្នើសុំធ្វើការកែប្រែ អ្នកត្រូវតែដាក់សំណើជាលាយលក្ខណ៍អក្សរ ទៅកាន់មន្ទីរពេទ្យដែលអ្នកទទួលការថែទាំសុខភាព។ អ្នកត្រូវតែបញ្ជាក់ពីមូលហេតុដែលអ្នកជឿជាក់ថាព័ត៌មានសុខភាពរបស់អ្នកមិនត្រឹមត្រូវឬមិនពេញលេញ។ ក្នុងករណីខ្លះ យើងអាចបដិសេធន៍សំណើសុំធ្វើការកែប្រែរបស់អ្នក។ ប្រសិនបើយើងបដិសេធន៍ យើងនឹងផ្តល់ជូនអ្នកនូវការពន្យល់ហេតុផលជាលាយលក្ខណ៍អក្សរ។

**<u>សិទ្ធិទទួលបានគណនេយ្យនៃការបង្ហាញព័ត៌មានសុខភាព៖</u>**
អ្នកមានសិទ្ធិស្នើសុំគណនេយ្យនៃការបង្ហាញព័ត៌មានសុខភាពរបស់អ្នកមួយចំនួនដែលធ្វើឡើងដោយ Agency។ នេះគឺជាបញ្ជីស្តីពីការបង្ហាញព័ត៌មាន ដែលយើងបានបង្កើតឡើងអំពីព័ត៌មានសុខភាពរបស់អ្នក ក្រៅពីការប្រើប្រាស់ផ្ទាល់ខ្លួនរបស់យើងសម្រាប់ការព្យាបាល ការបង់ប្រាក់ និងអាជីវកម្មថែទាំសុខភាព។ ដើម្បីស្នើសុំគណនេយ្យនៃការបង្ហាញព័ត៌មាន អ្នកត្រូវតែបញ្ជាក់ពីរយៈពេល ប៉ុន្តែមិនឲ្យលើសពីរយៈពេល ៦ ឆ្នាំឡើយ។ គណនេយ្យដំបូងដែលផ្តល់ជូននៅក្នុងរយៈពេល១២ខែគឺមិនគិតថ្លៃឡើយ។ យើងអាចគិតថ្លៃអ្នកសម្រាប់សំណើសុំនាពេលអនាគត។ មុននឹងយើងដំណើរការសំណើរបស់អ្នក យើងនឹងជម្រាបពីតម្លៃដើម្បីឲ្យអ្នកអាចប្តូរឬដកសំណើវិញ។

**<u>សិទ្ធិទទួលបានច្បាប់ចម្លងពីសេចក្តីជូនដំណឹង៖</u>**
អ្នកមានសិទ្ធិទទួលបានក្រដាសថតចម្លងនៃសេចក្តីជូនដំណឹងនេះនៅពេលណាក៏បាន ទោះបីជាអ្នកបានទទួលមួយច្បាប់រួចហើយ ឬបានព្រមព្រៀងទទួលសេចក្តីជូនដំណឹងនេះតាមអេឡិកត្រូនិក។ អ្នកអាចទទួលបានក្រដាសថតចម្លងសេចក្តីជូនដំណឹងនេះមួយច្បាប់ពីមន្ទីរពេទ្យដែលបានទទួលការថែទាំសុខភាព។ ច្បាប់ចម្លងសេចក្តីជូនដំណឹងតាមអេឡិកត្រូនិកក៏អាចរកបានពីវិបសៃថ៍របស់យើងដែរ៖ dhs.lacounty.gov, dmh.lacounty.gov ឬ publichealth.lacounty.gov។

## ការកែប្រែចំពោះសេចក្តីជូនដំណឹង

យើងអាចកែប្រែសេចក្តីជូនដំណឹងនេះនៅពេលច្បាប់ឬការអនុវត្តរបស់យើងមានការផ្លាស់ប្តូរ។ យើងរក្សាសិទ្ធិធ្វើឲ្យសេចក្តីជូនដំណឹងដែលបានពិនិត្យមើលឡើងវិញឬកែប្រែចូលជាធរមានស

ស្រាប់ព័ត៌មានសុខភាពដែលយើងមានរួចជាស្រេចអំពីអ្នក ព្រមទាំងព័ត៌មានទាំងឡាយណាដែលយើងទទួលនៅពេលអនាគត។
អ្នកនឹងមិនទទួលបានសេចក្តីជូនដំណឹងថ្មីដោយស្វ័យប្រវត្តិឡើយ។
ប្រសិនបើយើងកែប្រែសេចក្តីជូនដំណឹងនេះ យើងនឹងផ្សព្វផ្សាយសេចក្តីជូនដំណឹងដែលបានកែប្រែនោះនៅតាមមន្ទីរពេទ្យរបស់យើងនិងនៅលើវ៉ិបសៃថ៍ខាងលើ។
អ្នកក៏អាចទទួលបានសេចក្តីជូនដំណឹងដែលបានកែប្រែពីមន្ទីរពេទ្យដែលបានទទួលការថែទាំសុខភាពផងដែរ។

## របៀបដាក់បណ្តឹង

ប្រសិនបើអ្នកគិតថាពួកយើងរំលោភលើសិទ្ធិឯកជនភាពរបស់អ្នក អ្នកអាចដាក់បណ្តឹងជាមួយមន្ទីរពេទ្យដែលអ្នកទទួលការថែទាំសុខភាព ឬការិយាល័យណាមួយដែលមានរាយឈ្មោះខាងក្រោម។ ច្បាប់ហាមឃាត់ការសងសឹកប្រឆាំងនឹងបុគ្គលដែលដាក់បណ្តឹង។

County of Los Angeles
**Department of Health Services**
Private Officer
313 N. Figueroa Street, Room 703
Los Angeles, CA 90012
(800) 711-5366

County of Los Angeles
**Department of Mental Health**
Director of Patients' Rights Office
550 South Vermont
Los Angeles, CA 90020
(800) 700-9996

County of Los Angeles
**Department of Public Health**
Privacy Officer
1000 S. Fremont AVe
A9E, 5th Floor-South
Alhambra, CA 91803
(888) 228-9064

អ្នកក៏អាចដាក់បណ្តឹងជាមួយក្រសួងសេវាសុខភាពនិងមនុស្សសហរដ្ឋអាមេរិក ការិយាល័យសិទ្ធិពលរដ្ឋតាមលេខ (800) 368-1019 (TDD: 800-537-7697) ឬតាមលិខិតទៅកាន់៖

Region IX, Office for Civil Rights
U.S. Department of Health and Human Services
90 7th St. Suite 4-100
San Francisco, CA 94103

អ្នកក៏អាចដាក់បណ្តឹងតាមតំណភ្ជាប់នេះបានដែរ៖
**www.hhs.gov/ocr/privacy/hipaa/complaints/**